# សុន្ទរកថា និងរបាយការណ៍
## របស់ឯកឧត្តម បណ្ឌិត សោម ពិសិដ្ឋ អភិបាលនៃគណៈអភិបាលខេត្តកែប
## ក្នុងអង្គសន្និសីទសារព័ត៌មាន ស្តីពីភាពជោគជ័យក្នុងរយៈពេល ០៥ឆ្នាំ
## (២០១៨-២០២២)របស់រដ្ឋបាលខេត្តកែប

ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣

- *ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមលំឱនកាយក្រាបថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំង២ គណៈ ព្រមទាំងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាគោរពទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!*
- *សូមក្រាបថ្វាយបង្គំ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!*
- *សូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *សូមគោរពឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ជាទីគោរព!*
- *សូមគោរពសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រតិភូខេត្តកែប លោកយាយ លោកតា អ៊ុំ ពូ មាមីង បងប្អូនប្រជាពលរដ្ឋទាំងក្នុង និងក្រៅប្រទេស ពិសេសបងប្អូនប្រជាពលរដ្ឋខេត្តកែបទាំងអស់ ដែលកំពុងទស្សនាដំណើរការអង្គសន្និសីទសារព័ត៌មានស្តីពីភាពជោគជ័យក្នុងរយៈពេល ០៥ឆ្នាំ (២០១៨-២០២២) របស់រដ្ឋបាលខេត្តកែប នៅពេលនេះ ជាទីគោរព និងជាទីនឹករលឹក!*
- *ជម្រាបសួរបងប្អូនអ្នកសារព័ត៌មាន ជាទីរាប់អានដ៏ជ្រាលជ្រៅ!*

ថ្ងៃនេះ ក្នុងនាមថ្នាក់ដឹកនាំរដ្ឋបាលខេត្ត កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ ព្រះសង្ឃ សិស្ស និស្សិត និងប្រជាពលរដ្ឋខេត្តកែប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានមកចូលរួមធ្វើជាវាគ្មិនកិត្តិយសក្នុងសន្និសីទសារព័ត៌មានដ៏មានសារសំខាន់នៅពេលនេះ។ ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណ ចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំសន្និសីទសារព័ត៌មានស្តីពីភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក សម្រាប់រដ្ឋបាលខេត្តកែប និងបានផ្តល់ឱកាសឲ្យខ្ញុំព្រះករុណា ទូលព្រះបង្គំ ខ្ញុំបាទយើងខ្ញុំបានទូលថ្វាយ និងជម្រាបជូននូវវឌ្ឍនភាព និងសមិទ្ធិផលនានាដែលរដ្ឋបាលខេត្តកែបសម្រេចបាននាពេលកន្លងមក។ ជាមួយនេះខ្ញុំក៏សូមអរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ ដែលបានចូលរួមក្នុងសន្និសីទនេះ ប្រកបដោយមនោសញ្ចេតនាជ្រាលជ្រៅ និងភាពស្និទ្ធស្នាលយ៉ាងក្រៃលែង។

ខ្ញុំបាទក៏សូមការអនុញ្ញាតសម្តែងនូវការគោរពដឹងគុណបំផុត ដល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាអគ្គមហាបុរសរដ្ឋ ដែលមានមហាទេពកោសល្យដ៏ខ្ពង់ខ្ពស់បំផុត ប្រកបដោយគតិបណ្ឌិត និងជាស្ថាបនិកមគ្គុទេសក៏ឯក ជាប្រតិបត្តិករ

នយោបាយ **ឈ្នះ**! **ឈ្នះ**! នៅកម្ពុជា ដោយបានផ្ដើមចេញពីការយកអាយុជីវិតធ្វើជាដើមទុន ដើម្បីសង្គ្រោះអាយុជីវិតប្រជាជនកម្ពុជារាប់លាននាក់ ពីរបបប្រល័យពូជសាសន៍ **ប៉ុល ពត** និងបានដាក់ចេញនូវគោលនយោបាយស្ដារសេដ្ឋកិច្ចសង្គម ពីបាតដៃទទេ ពីគំនរផេះផង់ ឈានទៅរកការរីកចម្រើនផ្នែកសេដ្ឋកិច្ច នាំមកនូវមកនូវការអភិវឌ្ឍន៍ឥតឈប់ឈរ មានស្ថិរភាពនយោបាយ មានសុខសន្តិភាពពិតប្រាកដ ធ្វើឱ្យប្រជាពលរដ្ឋរស់នៅដោយភាពសុខសាន្ត ដែលមិនធ្លាប់មានក្នុងរយៈពេល ៥០០ឆ្នាំចុងក្រោយនៃប្រវត្តិសាស្ត្ររបស់កម្ពុជា។

ទន្ទឹមនេះ ក្នុងដំណាក់កាលនៃវិបត្តិជំងឺ covid-19 **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំប្រឹងប្រែង ក្នុងជួយសង្គ្រោះអាយុជីវិតប្រជាជនពីជំងឺដ៏កាចសាហាវនេះ ព្រមទាំងអាចរក្សាបានលំនឹងជីវភាពប្រជាជន រក្សាបានកំណើនសេដ្ឋកិច្ច ស្ថិរភាពសន្តិសុខ សុវត្ថិភាពសង្គមរឹងមាំ។ ប្រការនេះត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនូវសមត្ថភាពរបស់កម្ពុជាក្នុងការគ្រប់គ្រងការឆ្លងរីករាលដាល នៃជំងឺកូវីដ-19 បានល្អប្រសើរជាងបណ្ដាប្រទេសជាច្រើន ទាំងក្នុងកម្រិតតំបន់ និងសកលលោក ព្រមទាំងការសម្រេចបាននូវភាពស៊ាំសហគមន៍ពេញលេញ និងរឹងមាំដែលជួយធានានូវសុវត្ថិភាព និងសុខភាពសាធារណៈសម្រាប់ប្រជាជនកម្ពុជា តាមរយៈការផ្ដល់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដោយមិនប្រកាន់និន្នាការនយោបាយ ពូជន៍សាសន៍ និងពណ៌សម្បុរឡើយ។

ម៉្យាងទៀត ស្ថិតក្នុងបរិការណ៍នៃវិបត្តិអតិផរណាសេដ្ឋកិច្ចពិភពលោក **សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ក៏បានដឹកនាំប្រទេសគ្រប់គ្រងសភាពការណ៍បានយ៉ាងល្អប្រសើរ ទ្រទ្រង់ស្ថានភាពសេដ្ឋកិច្ចមិនឲ្យធ្លាក់ចុះខ្លាំង។ ដោយដាក់ចេញនូវអភិក្រមប្រតិបត្តិ ដែលមានភាពប្រាកដនិយម និងអាចអនុវត្តបាន ព្រមទាំងបានប្រែក្លាយពីការគំរាមកំហែង ទៅជាឱកាសសម្រាប់ការកែទម្រង់នៅក្នុងប្រទេស សំដៅឆ្ពោះសម្រេចបានគោលដៅនៃការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យរបស់ប្រទេសបានយ៉ាងល្អបំផុត។ យើងខ្ញុំមានមោទនភាពយ៉ាងក្រៃលែង ចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ក្នុងការសម្របសម្រួលដឹកនាំកិច្ចប្រជុំកំពូលអាស៊ាន លើកទី ៤០-៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលបានអនុម័ត និងកត់សម្គាល់នៅក្នុងបញ្ជីឯកសារសមិទ្ធផលជាង ១០០ឯកសារ ដើម្បីជាមគ្គុទេសក៏សម្រាប់សកម្មភាព និងសហប្រតិបត្តិការរបស់អាស៊ាននាឆ្នាំខាងមុខបន្តទៀត ដែលនេះគឺជាជោគជ័យយ៉ាងត្រចះត្រចង់ជាប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ក្នុងការបំពេញតួនាទីជាប្រធានអាស៊ានប្ដូរវេនក្នុងឆ្នាំ២០២២កន្លងទៅ ដែលបានលើកកម្ពស់តួនាទី និងកិត្យានុភាពរបស់កម្ពុជាយើងទាំងក្នុងតំបន់ និងលើឆាកអន្តរជាតិ។ ផ្អែកតាមសមិទ្ធផលជាច្រើនដែលបានកំពុងកកើតឡើងនៅក្រោមម្លប់សន្តិភាព យើងខ្ញុំទាំងអស់គ្នាប្ដេជ្ញាចិត្តរួមគ្នាថែរក្សារាល់សមិទ្ធផលរបស់ជាតិឲ្យបានគង់វង្ស ចូលរួមចំណែកក្នុងការកសាងប្រទេសជាតិឱ្យរីកចម្រើន ក្លាយជាប្រទេសជឿនលឿនមួយក្នុងតំបន់ ជាសង្គមប្រកបដោយអរិយធម៌ ការពារសន្តិភាពឱ្យបានដាច់ខាត និងសូមប្រឆាំងរាល់សកម្មភាពញុះញង់បំបែកបំបាក់ផ្ទៃក្នុងជាតិរបស់ក្រុមជនអគតិមួយក្ដាប់តូច។ សូមគាំទ្រយ៉ាងពេញទំហឹង **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាបេក្ខភាពនាយករដ្ឋមន្ត្រី សម្រាប់អាណត្តិទី៧ និងអាណត្តិក្រោយៗទៀត និងសូមគាំទ្រ **ឯកឧត្តម បណ្ឌិត ហ៊ុន ម៉ាណែត** ជាបេក្ខជននាយករដ្ឋមន្ត្រីសម្រាប់ពេលអនាគត។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមអនុញ្ញាតទូលប្រគេន និងជម្រាបជូនអំពីស្ថានភាពទូទៅ និងសមិទ្ធផលសំខាន់ៗ ដែលជាភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំ (២០១៨-២០២២) របស់រដ្ឋបាលខេត្តកែប ដោយសង្ខេបដូចតទៅ៖

## I.អំពីលក្ខណៈភូមិសាស្ត្រ

ខេត្តកែបស្ថិតនៅភាគនិរតី និងមានចម្ងាយប្រមាណ ១៧៥គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា តាមផ្លូវលេខជាតិលេខ៣ លេខ៣៣ និងមានផ្លូវរថភ្លើងឆ្លងកាត់ ០១ខ្សែ។ ខេត្តមានព្រំប្រទល់ខាងកើត ខាងជើង ខាងលិច ជាប់នឹងខេត្តកំពត និងខាងត្បូងជាប់តំបន់ទឹកប្រវត្តិសាស្ត្រកម្ពុជា-វៀតណាម។

- ទំហំផ្ទៃដីគោកសរុប ១៨៧,២៤គ.ម$^2$ មានឧទ្យានជាតិចំកណ្តាលទីក្រុងកែប និងតំបន់ភ្នំ
- មានកោះចំនួន១២ ថ្មប៉ប្រះទឹក ០១កន្លែង ថ្មដុះស្ងួត ០១កន្លែង និងមានផ្ទៃសមុទ្រ
- មានចំនួនក្រុង០១ និងស្រុក០១ មាន ០២ឃុំ ០៣សង្កាត់ ស្មើនឹង ១៨ភូមិ
- ប្រជាពលរដ្ឋចំនួន ២២,៨២២គ្រួសារ មនុស្សសរុប ៤៤,៥២៣នាក់ ស្រី ២២,៨២២នាក់ អាយុ ១៨ឆ្នាំឡើងមានចំនួន ២២,៨២២នាក់។ គិតជាដង់ស៊ីតេប្រជាពលរដ្ឋស្មើនឹង ២៣៨ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។
- មុខរបរចម្បងរបស់ប្រជាពលរដ្ឋគឺ៖ ធ្វើស្រែចំការ នេសាទសមុទ្រ កម្មកររោងចក្រ និងលក់ដូរ បម្រើសេវាកម្មទេសចរណ៍។

**សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា**!

ក្នុងរយៈពេល ៥ឆ្នាំកន្លងទៅនេះ ក្រោមម្លប់នៃសុខសន្តិភាព និងក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ការដឹកនាំសម្របសម្រួលរបស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** និងដោយមានការឧបត្ថម្ភ គាំទ្រពីក្រសួង ស្ថាប័ន ពីក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋានខេត្តកែប ដែលមានឯកឧត្តម **ជិន ម៉ិនស៊ាន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ជាប្រធាន ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានក្រុមការងារចុះជួយខេត្តកែប ដៃគូអភិវឌ្ឍ អង្គការ សមាគម និងវិស័យឯកជន គួបផ្សំនឹងការច្នៃប្រឌិត សម្របសម្រួលជាមួយមន្ទីរ អង្គភាព រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ធ្វើឲ្យការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (២០១៩-២០២៣) ផែនការអភិវឌ្ឍប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ខេត្ត សម្រេចបានលទ្ធផលការងារសំខាន់ៗដូចខាងក្រោម៖

## ១.ការងាររដ្ឋបាល និងសន្តិសុខ

### ១.១.ការងារសន្តិសុខ សណ្តាប់ធ្នាប់

ខេត្តបានដាក់ចេញនូវវិធានការសមស្របតាមគោលការណ៍ច្បាប់ ដោយធានាបានសន្តិសុខសុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈបានល្អប្រសើរ ជូនប្រជាពលរដ្ឋ ពិសេសឥស្សរ

ជនជាន់ខ្ពស់រាជរដ្ឋាភិបាល គណៈប្រតិភូជាតិ អន្តរជាតិ ព្រមទាំងភ្ញៀវទេសចរជាតិ អន្តរជាតិ ដែលមកបំពេញបេសកកម្ម និងមកទស្សនា សម្រាក លំហែ កំសាន្តក្នុងខេត្ត ធានាបានដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌអាណត្តិទី៣ ការបោះឆ្នោតជ្រើសតាំងព្រឹទ្ធសភានីតិកាលទី៤ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដោយរលូន និងស្របតាមច្បាប់ដែលបានកំណត់។ ជាមួយនេះ បានមានវិធានការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពប៉ុនប៉ងធ្វើរដ្ឋប្រហារពីសំណាក់ពួកឧទ្ទាមក្រៅច្បាប់ និងចលនាបដិវត្តន៍ពណ៌ ការទប់ស្កាត់អំពើជួញដូរមនុស្ស ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ការបំផ្លិចបំផ្លាញធនធានធម្មជាតិ។ល។ បង្ការទប់ស្កាត់ និងការបង្រ្កាបបទល្មើសគ្រប់ប្រភេទ សហប្រតិបត្តិការល្អជាមួយខេត្តគៀនយ៉ាង ប្រទេសវៀតណាម និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានភូមិសាស្រ្តជាប់គ្នា។ លើការងារអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ជាលទ្ធផលឃុំ សង្កាត់ទាំង៥ របស់ខេត្តសុទ្ធតែទទួលបាននូវចំណាត់ថ្នាក់ប្រភេទល្អ។

## ១.២.ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ

អនុវត្តតាមកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃប្រទេសទាំង២ (កម្ពុជា-វៀតណាម) រដ្ឋបាលខេត្តកែបបានយកចិត្តទុកដាក់ធ្វើកិច្ចសហប្រតិបត្តិការល្អជាមួយខេត្តគៀនយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ទាំងការងារសន្តិសុខលើតំបន់ទឹកប្រវត្តិសាស្រ្ត ការទប់ស្កាត់បទល្មើសឆ្លងដែន។ ជាមួយនេះ ភាគីទាំង២តែងតែជួបប្រជុំថ្នាក់ខេត្ត និងថ្នាក់អង្គភាពជំនាញទៅតាមរបបប្រជុំយ៉ាងទៀតទាត់ សំដៅលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងជួយគ្នាទៅវិញទៅមក ក្នុងនាមជាអ្នកភូមិផងរបងតែមួយ និងដោះស្រាយបញ្ហាបាតុភាពអសកម្មផ្សេងៗបានទាន់ពេលវេលា។

## ១.៣.ការងារផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយ

យន្តការសម្រាប់ផ្តល់សេវាជូនប្រជាពលរដ្ឋមាន ០៣ថ្នាក់ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព នៃការផ្តល់សេវារដ្ឋបាលលើវិស័យនានានៅកន្លែងតែមួយ។ រដ្ឋបាលខេត្តបានរៀបចំជួសជុលបន្ទប់អគារអង្គភាពច្រកចេញចូលតែមួយខេត្ត ដែលផ្តល់សេវាលើ ១៤វិស័យ, ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុកទាំង២ និងបានដាក់ឲ្យដំណើរការយន្តការច្រកចេញចូលតែមួយសេវាអត្តសញ្ញាណកម្មនៅថ្នាក់សាលាឃុំ សង្កាត់ ទូទាំងក្នុងខេត្ត ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ។ ការផ្តល់សេវាតាមយន្តការច្រកចេញចូលតែមួយ ត្រូវបានទទួលការគាំទ្រ និងសាទរពីប្រជាពលរដ្ឋ ដែលជាអ្នកមកស្នើសុំសេវា ដោយសាររាជរដ្ឋាភិបាលបានបង្វិតសេវាឲ្យកាន់តែកៀកជិតប្រជាពលរដ្ឋ ហើយនីតិវិធីមានលក្ខណៈសាមញ្ញ ឆាប់រហ័ស តម្លាភាព គណនេយ្យភាព ភាពជឿទុកចិត្តបាន។

ជាក់ស្តែងក្នុងរយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ សេវាដែលបានផ្តល់ជូនដោយអង្គភាពច្រកចេញចូលតែមួយខេត្ត ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក យន្តការច្រកចេញចូលតែមួយសេវាអត្តសញ្ញាណកម្មនៅថ្នាក់ឃុំ សង្កាត់ បានផ្តល់សេវាជូនប្រជាពលរដ្ឋសរុបមានចំនួន **៧៧.៣៥៤សេវា**។

## ១.៤.អំពីការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ

ក្នុងដំណើរការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ រដ្ឋបាលខេត្តប្រើប្រាស់វិធីសាស្ត្រដោះស្រាយតាមយន្តការដែលមានស្រាប់ និងតាមជំនាញពាក់ព័ន្ធនីមួយៗមានទាំងចំហរ និងចង្អៀតផង។

ជាលទ្ធផលរដ្ឋបាលខេត្តបានធ្វើការសម្រុះសម្រួលដោះស្រាយទំនាស់ តាមពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋរួមមាន៖ ទទួលពាក្យបណ្តឹង ១៧៩, កំពុងដោះស្រាយ ៥២, ដោះស្រាយរួច ៨៩, ច្រានចោល ៤៩, ដកពាក្យបណ្តឹង ២១, បញ្ជូនទៅគណៈកម្មការក្រុង-ស្រុក ដោះស្រាយមានចំនួន ៤៤ករណី។

## ២.ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- ❖ បានរៀបចំកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ មន្ទីរ អង្គភាពជុំវិញខេត្ត អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងប្រជាពលរដ្ឋ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។
- ❖ ក្រសួងស្ថាប័នបានផ្ទេរមុខងារធនធានមួយចំនួនមកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើការគ្រប់គ្រងស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្អែកតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។ បុគ្គលិកដែលបានផ្ទេរមកឱ្យរដ្ឋបាលខេត្ត ក្រុង ស្រុកនៃខេត្តកែបមានចំនួន ២៤០នាក់ ស្រី ១០៣នាក់ ក្នុងនោះរដ្ឋបាលខេត្តចំនួន ៦៣នាក់ ស្រី ១៩នាក់ រដ្ឋបាលក្រុងចំនួន ១៥នាក់ ស្រី ៥នាក់ រដ្ឋបាលស្រុកចំនួន ១៦នាក់ ស្រី ៣នាក់ និងមន្ត្រីសុខាភិបាលចំនួន ១៤៦នាក់ ស្រី ៧៦នាក់។

### • កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

គម្រោងដែលបានអនុវត្តរួមមាន៖ ផ្នែកសេដ្ឋកិច្ច ២២២គម្រោង ផ្នែកសង្គមកិច្ច ៣៥៦គម្រោង ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ៣៤គម្រោង ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ **១២៥**គម្រោង សរុបមានចំនួន **៧៣៧**គម្រោង។

### • កម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក

គម្រោងដែលបានអនុវត្តរួមមាន៖ ផ្នែកសេដ្ឋកិច្ច **១៣៣**គម្រោង ផ្នែកសង្គមកិច្ច **១៥៤**គម្រោង ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ **៥០**គម្រោង ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ **៩៣**គម្រោង សរុបមានចំនួន **៤៣០**គម្រោង។

### • កម្មវិធីវិនិយោគឃុំ សង្កាត់

គម្រោងដែលបានអនុវត្តរួមមាន៖ ផ្នែកសេដ្ឋកិច្ច **៦២**គម្រោង ផ្នែកសង្គមកិច្ច **១១២**គម្រោង ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ **៣៦**គម្រោង ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ **២៥**គម្រោង សរុបមានចំនួន **២៣៥**គម្រោង។

ជារួមគម្រោងវិនិយោគបីឆ្នាំរំកិលថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ សរុបមានចំនួន ១.៤០២គម្រោង ដែលបានឆ្លើយតបជាបន្តបន្ទាប់ទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

## ៣-សមិទ្ធផលអនុវត្តដោយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.១.ថវិកាគុណប្រយោជន៍រដ្ឋបាលខេត្ត

បានបន្តជំរុញយ៉ាងសកម្មក្នុងការកែលម្អសោភណភាពតាមដងផ្លូវ គេហដ្ឋាន ទីសាធារណៈ រមណីយដ្ឋានទេសចរណ៍ ឆ្នេរកំសាន្ត និងសាងសង់កែលម្អនូវសមិទ្ធផលសំខាន់ៗ ការសាងសង់អគាររដ្ឋបាល សួនច្បារ ដាក់បង្គោលភ្លើងបំភ្លឺតាមផ្លូវសាធារណៈ និងទីប្រជុំជន ដាក់រូបសំណាកថ្មីៗ ការបង្កើតកន្លែងហាត់ប្រាណ ស្ពានា កែលម្អផ្លូវក្រាលកៅស៊ូAC ផ្លូវកៅស៊ូDBST និងសំណង់សិល្បការព្យចាំបាច់មួយចំនួន។ល។ ព្រមជាមួយនេះ យើងបានបណ្តុះបណ្តាលជំនាញបដិសណ្ឋារកិច្ច អនាម័យម្ហូបអាហារជូនដល់ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ បង់ហ្គាឡូ វីស្សេត ភោជនីយដ្ឋាន អាហារដ្ឋាន និងប្រតិបត្តិករទេសចរណ៍ ការរៀបចំទិវាអនាម័យបរិស្ថាន និងបានដឹកនាំមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ សិស្ស និស្សិត និងបំផុសប្រជាពលរដ្ឋ អាជីវករធ្វើអនាម័យបរិស្ថាន ការដាំដើមឈើ ដើម្បីបំពេញសម្បទាទេសចរណ៍ ស័ក្តិសមជាទីក្រុងទេសចរណ៍ធម្មជាតិដែលមានបរិស្ថានបៃតងគ្រប់ទីកន្លែង និងគ្រប់រដូវកាល។

**គម្រោងកែលម្អសោភណភាពខេត្តរួមមាន៖**

- ជួសជុលផ្លូវក្រាលកៅស៊ូ DBST ចំនួន ២៨ខ្សែ ប្រវែងសរុប ២០.៥៧៩ម៉ែត្រ និងសំណង់សិល្បការព្យតាមបណ្តោយផ្លូវស្ថិតនៅភូមិសាស្ត្រក្រុង ស្រុក
- ជួសជុលផ្លូវក្រួសក្រហមចំនួន ០១ខ្សែ ប្រវែង ៤.៨៩០ម៉ែត្រ
- ជួសជុលផ្លូវចាក់មេតុងអាមេចំនួន ៨ខ្សែ ប្រវែង ៩.៤៨៩ម៉ែត្រ
- ជួសជុលផ្លូវអ៊ុតកៅស៊ូACចំនួន ១៣ខ្សែ ប្រវែង ៤.០៩៩ម៉ែត្រ
- គម្រោងសាងសង់សាលប្រជុំស្តង់ដារជំហាន៤ មានបណ្តោយ ៣៤.៤ម៉ែត្រ ទទឹង២១.២ម៉ែត្រ ស្ថិតនៅភូមិកែប សង្កាត់កែប
- គម្រោងរៀបខឿនច្រាំងសមុទ្រ និងចាក់ខ្សាច់បំពេញឆ្នេរប្រវែង ៧៥ម៉ែត្រ ជម្រៅ ៩០ម៉ែត្រ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប
- គម្រោងដាំបង្គោលភ្លើង និងតបណ្តាញអគ្គិសនីបភ្លឺសាធារណៈចំនួន២៥០បង្គោល តាមសួនច្បារផ្លូវ៣៣អា ចាប់ពីរង្វង់មូលសេះស ដល់រង្វង់មូលមុខមន្ទីរទេសចរណ៍ខេត្តកែប ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ
- តបណ្តាញអគ្គិសនី និងដាក់ដងគោមភ្លើងបំភ្លឺផ្លូវសាធារណៈចំនួន ១៦៨បង្គោល តាមដងផ្លូវក្នុងក្រុង
- សាងសង់អគារច្រកចេញចូលតែមួយរដ្ឋបាលស្រុកដំណាក់ចង្អើរ០១ខ្នងទំហំ ២០ម X ១០ម ស្ថិតនៅភូមិភ្នំលាវ ឃុំពងទឹក
- រៀបច្រាំងសមុទ្រ និងចាក់ខ្សាច់បំពេញ ប្រវែង១៤០ម៉ែត្រ ទទឹង២០ម៉ែត្រ កម្ពស់ ៥ម៉ែត្រ ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ
- សាងសង់ស្តូបតម្កល់រូបសំណាកព្រះបាទជ័យវរ្ម័នទី៧ ចំនួន ០២ទីតាំង
- សាងសង់ឈាបនដ្ឋាន ០១កន្លែង ទីតាំងស្ថិតនៅភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ក្រុងកែប
- សាងសង់ទីលានទុកដាក់សំរាម ០១កន្លែង ស្ថិតនៅភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ក្រុងកែប

## ៣.២.ថវិកាមូលនិធិក្រុង ស្រុក៖

### ៣.២.១ គម្រោងអភិវឌ្ឍន៍មូលនិធិក្រុងកែប

ក្នុងរយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ រដ្ឋបាលក្រុងបានសាងសង់ផ្លូវលំក្រួសក្រហមបានចំនួន ០១ខ្សែ ប្រវែង ៨៥០ម៉ែត្រ ចំណាយថវិកាចំនួន ៩០.៦០០.០០០រៀល ផ្លូវបេតុងចំនួន ០៤ខ្សែ ប្រវែង ១.៣៩១ម៉ែត្រ ចំណាយថវិកាចំនួន ៥៤៨.៤៧៨.១៤៦រៀល សរុបថវិការយៈពេល ៥ឆ្នាំចំនួន ៦៣៩.០៧៨.១៤៦រៀល។

**៣.២.២ គម្រោងអភិវឌ្ឍន៍មូលនិធិស្រុកដំណាក់ចង្អើរ**

រដ្ឋបាលស្រុកបានកសាងផ្លូវលំក្រួសក្រហមបានចំនួន ០៥ខ្សែ ប្រវែង ៧.៩៥០ម៉ែត្រ ទទឹង ០៤ម៉ែត្រ នៅភូមិអន្ទង់ស និងភូមិចំការចេក ក្នុងឃុំពងទឹក និងភូមិអង្កោល ភូមិអំពេង ភូមិទួលសាង៉ាក្នុងឃុំអង្កោល។

**៣.២.៥ថវិកាមូលនិធិឃុំ សង្កាត់**

-បានជួសជុលផ្លូវក្រួសក្រហមចំនួន១៧ខ្សែ ប្រវែង ៤៤.៩៥០ម៉ែត្រ តម្លៃសរុប ៣.៣៣០.៤០៦.៥០០រៀល។

-គម្រោងផ្លូវបេតុងចំនួន ០៥ខ្សែ ប្រវែង ២.១៨១ម៉ែត្រ តម្លៃសរុប ៩១៣.២២០.០០០រៀល

**អំពីការសាងសង់ និងជួសជុលអគាររដ្ឋបាលមន្ទីរ អង្គភាព**

ក្នុងរយៈពេល៥ឆ្នាំនេះ អគាររដ្ឋបាលតាមមន្ទីរ អង្គភាព ដែលបានជួសជុលអគារចំនួន ១១អគារ ជួសជុលស្នាក់ការឧទ្យាន ០១អគារ ជួសជុលអគារស្នាក់នៅរបស់មន្ត្រី ០១ខ្នង និងសាងសង់អគាររដ្ឋបាលចំនួន ០៦អគារ សាងសង់អគារបណ្តុះបណ្តាលវិជ្ជាជីវៈ ០១អគារ សាងសង់អគារស្នាក់នៅរបស់មន្ត្រី ០១ខ្នង សាងសង់ប៉ុស្តិ៍ការពារ ០២កន្លែង សាងសង់សាលប្រជុំ ០១អគារ និងអគារសិក្សាដែលបានសាងសង់ថ្មីសរុបចំនួន ១៧ខ្នង ស្មើនឹង ២៣៧បន្ទប់។

## ៤-ការងារវិនិយោគ

ក្រុមហ៊ុនវិនិយោគ ដែលទទួលបានការអនុញ្ញាតធ្វើការវិនិយោគនៅខេត្តកែបក្នុងរយៈពេល ៥ឆ្នាំនេះរួមមាន៖ ផ្គត់ផ្គង់សេវាអគ្គិសនី, រមណីយដ្ឋានរ៉ូតុង, អាជីវកម្មថ្មសំណង់, រមណីយដ្ឋាន ឌី សាន់ វីយូ រីស្សត, សាងសង់ផ្សារដំណាក់ចង្អើរថ្មី, សាងសង់ផ្សាររាត្រី, សាងសង់ចំណតជលយាន្ត (កំពង់ផែសេះស),សាងសង់មណ្ឌលកំសាន្ត និងអភិវឌ្ឍន៍បរិវេណឆ្នេរ, គម្រោងខ្សែរ៉ក ZIP LINE ចំណតជលយានទេសចរណ៍ និងអនាម័យឆ្នេរចាក់ខ្សាច់ថ្មី និងការវិនិយោគបង្កើតទីក្រុងរណបជាប់ឆ្នេរសមុទ្រ។ល។

ជាមួយនេះ គម្រោងវិនិយោគដែលទទួលបានគោលការណ៍ពីរាជរដ្ឋាភិបាលរួចហើយមានដូចជាគម្រោងវិនិយោគតាមបណ្តាកោះ និងតំបន់ការពារធនធានធម្មជាតិ(តំបន់ឧទ្យានជាតិកែប)រួមមាន៖

១.គម្រោងវិនិយោគតាមបណ្តាកោះ៖ កោះទន្សាយ កោះពោធិ៍ កោះត្បាល់ កោះការ៉ាង កោះស្វាយ កោះកុក និងកោះម្ទេស។

២.គម្រោងវិនិយោគតំបន់ការពារធនធានធម្មជាតិ (តំបន់ឧទ្យានជាតិកែប)៖ គម្រោងវិនិយោគអេកូទេសចរណ៍ខ្នាតតូចជាច្រើនគម្រោងដែលមានស្នើសុំវិនិយោគ។

## ៥-ការងារយុត្តិធម៌

ជាប្រវត្តិសាស្ត្រ ខេត្តកែបត្រូវបានបង្កើតឱ្យមានសាលាដំបូងខេត្ត មានពន្ធនាគារខេត្តកែបជាផ្លូវការហើយ និងបានប្រកាសជាខេត្តទី១ អស់មីនដំបូងគេបង្អស់នៅព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីបាន

បញ្ចប់សង្គ្រាមស៊ីវិល ក្រោមនយោបាយ **ឈ្នះ! ឈ្នះ!** របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាកំពូលស្ថាបនិក និងមគ្គុទេសក៍ឯកនៃសន្តិភាពនៅកម្ពុជា។

## ៦.សមិទ្ធផលតាមវិស័យជំនាញ

### ៦.១.វិស័យកសិកម្ម និងធារាសាស្ត្រ

**-ដំណាំស្រូវ៖** មានផ្ទៃដីដាំដុះចំនួន **៣.៦០៣ហិកតា** ទិន្នផលស្រូវ ៣,៣៨៥ត/ហត បរិមាណផលស្រូវ ៥៩.៣៣៣តោន។

**-ដំណាំអចិន្ត្រៃយ៍(ទុរេន,ស្វាយ,ម្រេច)** ផ្ទៃដីដាំដុះ **១.៣៦៨ហិកតា** បរិមាណផល ៨៤.៩៤៥ តោន។

**-ចិញ្ចឹមសត្វ៖** សត្វពាហនៈ(គោ ក្របី ជ្រូក) មានចំនួន ២៦.០៥៥ក្បាល។

ក្នុងរយៈពេល ៥ឆ្នាំនេះ វិស័យធនធានទឹក បានជួសជុលប្រព័ន្ធធារាសាស្ត្រទំនប់អាងទឹកចំនួន ០៨កន្លែង ស្មើនឹង ១៩.០៩០ម៉ែត្រ ថែទាំ និងជួសជុលជាប្រចាំប្រព័ន្ធធារាសាស្ត្រ ០៥ប្រព័ន្ធ ប្រវែង ៦.៧២៦,៤ម៉ែត្រ ស្តារប្រឡាយបានចំនួន ១២ខ្សែ ប្រវែង ២៧.២១៣ម៉ែត្រ ជួសជុល និងប្តូរទ្វារទឹក ០២កន្លែង ដាក់លូបង្ហូរទឹកចូលប្រឡាយ ០៨កន្លែង សាងសង់រោងសហគមន៍កសិកររប្រើប្រាស់ទឹក ០១ខ្នង បំពាក់ឧបករណ៍ឧតុនិយមស្វ័យប្រវត្តិ ០១ស្ថានីយ៍ ជួសជុលអគារស្ថានីយ៍ឧតុនិយម ០១ កន្លែង ដោយបំពាក់ឧបករណ៍វាស់កម្រិតទឹកភ្លៀង។

### ៦.២.វិស័យគមនាគមន៍

**ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងទីប្រជុំជន**

- ជួសជុលផ្លូវដោយចាក់អ៊ិតបេតុងកៅស៊ូA/C ប្រវែង ១៨.៧០៥គ.ម
- ជួសជុលផ្លូវដោយក្រាលកៅស៊ូពីស្រទាប់ DBST ប្រវែង ១៩.៨៦គ.ម
- ជួសជុលផ្លូវដោយចាក់បេតុងសរសៃដែក RC ប្រវែង១,៤១ គ.ម
- ជួសជុលផ្លូវដោយក្រាលដីល្បាយថ្មភ្នំ ប្រវែង ៨,២៨០ម៉ែត្រ
- ជួសជុល និងថែទាំផ្លូវជាលក្ខណៈខួបក្រាលល្បាយថ្មភ្នំប្រវែង ៦៥,៤៨ គ.ម
- ជួសជុល និងថែទាំផ្លូវជាលក្ខណៈប្រចាំក្រាលថ្មភ្នំ ប្រវែង ១៨៦,១៤៤ គ.ម
- ជួសជុលផ្លូវអន្តរាគមន៍បន្ទាន់ ប្រវែង ១៦,៣០គ.ម
- ស្ថាបនាផ្លូវលំក្រួសក្រហម ប្រវែង ២៣,៤៩៥ គ.ម
- ស្ថាបនា និងជួសជុលផ្លូវលំដីស ប្រវែង ៣៩,៩៦១ គ.ម
- ផ្លូវបេតុង ប្រវែង ០,៧៨១ គ.ម
- ដាក់លូប្រអប់មុខ០២ កាត់ទទឹងផ្លូវ ប្រវែង ៤៨ម និងលូមូល ២៥ម៉ែត្រ
- សាងសង់សំណង់សិល្បការ្យ ប្រវែង ៥,១៣៦ម៉ែត្រ
- ដំឡើងអំពូលប្រើថាមពលពន្លឺព្រះអាទិត្យ និងខ្យល់ ប្រវែង ១០១បង្គោល
- កសាងសួនច្បារពុះទ្រូងផ្លូវ ប្រវែង ១,១២០ ម៉ែត្រ
- ការរៀបចំផ្លូវថ្មើរជើង (រៀបការ៉ូឡា) ប្រវែង ២,២ គ.ម

- ការងាររៀបជញ្ជាំងថ្មទប់ដី(ប្រអប់សំណាញ់)ការពារបាក់ច្រោះជើងភ្នំផ្លូវជាតិលេខ ៣៣A ប្រវែង ៦៤ម៉ែត្រ

- ការងារស្ថាបនាទំនប់ក្រវាត់ដោយចាក់បំពេញថ្ម (បំបែកពីផ្លូវជាតិលេខ៣៣A ខាងត្បូងផ្សារក្តាម) ប្រវែង ២០០ម៉ែត្រ

- សាងសង់អាងប្រព្រឹត្តិកម្មអាងចម្រោះទឹកកខ្វក់នៅតំបន់ផ្សារក្តាម ០១កន្លែង

- សាងសង់ស្ថានីយថ្លឹងរថយន្តអចល័ត (ផ្លូវជាតិលេខ៣៣) ០១កន្លែង

- គម្រោងសាងសង់ផែកែប-កោះទន្សាយ លើទីតាំងផែចាស់ អនុវត្តការងារដោយនាយកដ្ឋានហេដ្ឋារចនាសម្ពន្ធដឹកជញ្ជូនផ្លូវទឹកនៃក្រសួងសាធារណការ និងដឹកជញ្ជូន ០១កន្លែង។

## ៦.៣.វិស័យពាណិជ្ជកម្ម

**-ទិន្នន័យផលិតផល-កសិផលនាំចេញសំខាន់ៗរួមមាន៖** ម្រេចG.Iកំពត ១៣៥.៣តោន, ស្វាយកែវរមៀត ៤៩.៣៨៨តោន, ផលិតផលជលផលសមុទ្រ ២៨.៥៥៧តោន។

**-ការងារជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច** បានសម្រេចចងក្រងក្រុមកសិករផលិត ១.៣៧៥ គ្រួសារ, បណ្តុះបណ្តាលចំណេះដឹងអាជីវកម្ម និងទីផ្សារ ១៣១វគ្គ, បង្កើតកិច្ចសន្យាទិញលក់កសិផល (មាន់ស្រែ បន្លែ ស្រូវ) ៨០កិច្ចសន្យា,ទំហំទឹកប្រាក់សរុបនៃកិច្ចសន្យាទិញលក់កសិផល ៤.៥២០លានរៀល។

## ៦.៤.វិស័យរ៉ែ និងថាមពល

ខេត្តកែបមានអាជ្ញាប័ណ្ណរ៉ែ ១៣ទីតាំង ក្នុងនោះមាន អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មសំណង់ ០១ទីតាំង និងអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មសម្រាប់ធ្វើអាជីវកម្មដីក្រហម (ឡាតេរីត)១២ទីតាំង។ អតិថិជនប្រើប្រាស់ថាមពលអគ្គិសនីចំនួន ៨.៣៦៥ខ្នងផ្ទះ ស្មើនឹង ៩៤,៦៧% និងមានស្ថានីយប្រេងឥន្ទនៈចំនួន ២០ទីតាំង។

## ៦.៥.វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ទូទាំងខេត្តមានសិប្បកម្ម ១៨៧ទីតាំង ផ្ទៃដីផលិតអំបិល ៩៩៥,១២ហិកតា អំបិលផលិតបាន ១០,០៣៣តោន ក្រុមសាមគ្គីផលិតអំបិល ២១មូលដ្ឋាន, បរិមាណផលិតទឹកស្អាត ១.៣៦៨.៧៩៩ម$^{៣}$, ប្រវែងបណ្តាញទឹកស្អាត ៨៦.៣៣៧ម, គ្រួសារដែលមានទឹកស្អាតប្រើប្រាស់ ៤០%។

## ៦.៦.វិស័យទេសចរណ៍៖

មានសណ្ឋាគារ១៧ ផ្ទះសំណាក់៥៨ ប៊ឹងហ្គាឡូវីសត២១ អាហារដ្ឋាន និងភោជនីយដ្ឋាន ៣៤ ស្ប៉ាសូណា និងម៉ាស្សា៣ ខារ៉ាអូខេ ៨ ក្លឹបកម្សាន្ត១ មណ្ឌលព័ត៌មានទេសចរណ៍៣ ទូកដឹកភ្ញៀវទេសចរ ១៦។ បានផ្តល់អាជ្ញាប័ណ្ណទេសចរណ៍៤០៦។ ក្នុងរយៈពេល ៥ឆ្នាំ កន្លងមកភ្ញៀវទេសចរដែលបានមកសម្រាកលម្ហែនៅខេត្តកែបសរុបមានចំនួន ៦.៧០៤.០៣៥ ក្នុងនោះភ្ញៀវជាតិ **៦.៥៥១.២៣១នាក់** ភ្ញៀវអន្តរជាតិ **១៥២.៨០៤**នាក់។ បានសហការរៀបចំផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តកែប (២០២១-២០៣៥)។ បានបង្កើតសហគមន៍អេកូទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ភ្នំសរសៀផ្ទាំង២០២១ និងផ្លូវបេតុងក្រវ៉ាត់ជុំវិញភ្នំកែបធំ ក្នុងតំបន់ឧទ្យានជាតិ ក្រោមការជួយឧបត្ថម្ភគាំទ្រពីឯកឧត្តម បណ្ឌិត **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន។ សណ្ឋាគារ១៥កន្លែង ផ្ទះសំណាក់ ៥៩កន្លែង ប៊ឹងហ្គាឡូវីសត ២៧កន្លែង អាហារដ្ឋាន និង

ភោជនីយដ្ឋាន ៣៩កន្លែង ស្ប៉ាសូណា និងម៉ាសស្សា ៣កន្លែង ខារ៉ាអូខេ ៦កន្លែង ម៉ូតូរ៉ឺម៉ក់ដឹកភ្ញៀវ មណ្ឌលព័ត៌មានទេសចរណ៍ ទូកដឹកភ្ញៀវទេសចរ បោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍បច្ចុប្បន្នកម្ម ខេត្តកែបឆ្នាំ២០២១-២០២៥បោះពុម្ពប័ណ្ណផ្នត់ផែនទីទេសចរណ៍ គោលដៅទាក់ទាញទេសចរណ៍។

## ៦.៧. ការចាប់ប្រឡងប្រណាំង និងការទទួលពានរង្វាន់

-ជ័យលាភី «ទីក្រុងទេសចរណ៍ស្អាតអាស៊ាន » ទទួលនៅទីក្រុងឈាងម៉ៃប្រទេសថៃ

-ពានរង្វាន់សណ្ឋាគារបៃតងអាស៊ាន ទទួលនៅទីក្រុងឈាងម៉ៃប្រទេសថៃ

-ជ័យលាភីផ្ការំដួល ៣ទងលើកទី២ ទទួលនៅរាជធានីភ្នំពេញ

-ជ័យលាភីឆ្នេរខ្សាច់ស្អាត ទទួលនៅរាជធានីភ្នំពេញ

-ជ័យលាភីទីក្រុងដែលមានពិធីបុណ្យឆ្លងឆ្នាំសកលល្អជាងគេប្រចាំឆ្នាំ «២០១៨-២០១៩»

-ជ័យលាភីស្នាមញញឹម ៣ និងស្នាមញញឹម២ ទទួលនៅរាជធានីភ្នំពេញ

-ពានរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ "លើកទី៣"

-ពានរង្វាន់ជ័យលាភីទីក្រុងស្អាតផ្ការំដួល ៣ទង លើកទី៣

-ពានរង្វាន់ខ្យល់ស្អាត ទីក្រុងនិរន្តរភាពបរិស្ថានអាស៊ាន ទទួលនៅប្រទេសឥណ្ឌូនេស៊ី

ព្រមទាំងទទួលបាននូវស្នាដៃលើការដឹកនាំជាច្រើនជាបន្តបន្ទាប់ទៀត។

## ៦.៧.វិស័យធនធានធម្មជាតិ និងបរិស្ថាន

ខេត្តមានព្រៃកោងកាងចំនួន ៣កន្លែង មានផ្ទៃក្រឡា **១.00៥**ហិកតា ស្មៅសមុទ្រ **៣.0៩៥**ហិកតា ផ្កាថ្ម **៥២,៥ហិកតា** និងមានធនធានធម្មជាតិមានត្រីផ្សោត ជ្រូកទឹក អណ្តើកសមុទ្រ ត្រីសេះ ក្តាមសេះ ដែលមានរស់ជាតិឆ្ងាញ់ ធនាគារក្តាម ៤កន្លែង ទូកនេសាទ ៧២៨គ្រឿង និងឧទ្យានជាតិកែបមានទំហំ **១.១៥២ហិកតា**។ ធនធានធម្មជាតិទាំងនេះ ត្រូវបានអភិរក្ស និងប្រើប្រាស់ប្រកបដោយនិរន្តរភាព។ បានបោះបង្គោលព្រំឧទ្យានជាតិកែប ចំនួន **៩៣បង្គោល** ដាំផ្កាធ្វើសួនច្បារគំរូ និងការថែទាំ **៦00ម៉ែត្រ** ធ្វើអាងប្រព្រឹត្តកម្មសាធារណៈ**៥គម្រោង** បំពាក់ឡដុតសំរាមសំណល់រឹងវេជ្ជសាស្ត្រ និងសំណល់គ្រោះថ្នាក់ផ្សេងៗ**១គម្រោង** ដាំកូនឈើបាន **៥១.0៨៦ដើម** ដាក់ធុងសំរាមនៅតាមទីសាធារណៈ និងសួនច្បារនានាក្នុងខេត្ត ៥៣៤ធុង ដាក់ស្លាកប៉ាណូអប់រំផ្សព្វផ្សាយបរិស្ថាន ៩៥ស្លាក និងបានធ្វើផ្លូវបេតុងជុំវិញឧទ្យានជាតិកែបប្រវែង ៦.000ម៉ែត្រ។

## ៦.៨.វិស័យពន្ធដារ

ក្នុងរយៈពេល ៥ឆ្នាំ(២០១៨-២០២២) ចំណូលពន្ធ-អាករគ្រប់ប្រភេទដែលសាខាពន្ធដារខេត្តកែបប្រមូលបានសរុបមានចំនួន ៥៣.៩៧៥.៤២៨.០៤១រៀល (ប្រមាណជា ១៣.៤៩៣.៨៥៧ ដុល្លារអាមេរិក) ក្នុងនោះថវិកាជាតិមានចំនួន ១១.៧២៥.០៧១.៥៩៧រៀល និងថវិកាថ្នាក់ក្រោមជាតិមានចំនួន ៤២.២៥០.៣៥៥.៨៩១រៀល។

ជារួមដោយសារមានការខិតខំយកចិត្តទុកដាក់ក្នុងការជំរុញ ស្ថានភាពនៃការប្រមូលពន្ធ និងអាករនានាធៀបជាមួយផែនការប្រចាំឆ្នាំគឺមានកើនឡើងលើសផែនការជារៀងរាល់ឆ្នាំ។

## ៦.៩.វិស័យផែនការ

បានផលិតឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមកិច្ច និងឯកសារពិន្ទុវិស័យខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ សម្រាប់គាំទ្រដំណើរការរៀបចំកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល។ នៅរដ្ឋបាលថ្នាក់ក្រោមជាតិទំហំសេដ្ឋកិច្ចខេត្តមាន ២១៨,៥៣២លានរៀល គិតជាដុល្លារ ប្រហែល ៥៤លានដុល្លារអាមេរិក ស្មើ០.២% នៃសេដ្ឋកិច្ចជាតិ។ សេដ្ឋកិច្ចខេត្តមានកំណើន ០.៣% នៅឆ្នាំ២០២១ ធៀបនឹងឆ្នាំ២០២០។ ចំណូលសម្រាប់មនុស្សម្នាក់មានចំនួន ១,២០៦ ដុល្លារអាមេរិចនៅឆ្នាំ២០២១។

អត្រាភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងខេត្ត ២.៦១ នៅឆ្នាំ២០២២។

### ៦.១០.វិស័យព័ត៌មាន

បានដំឡើងអង់តែនម៉ាស៊ីនផ្សាយសម្លេងវិទ្យុជាតិ FM 99MHz ០១អង់តែន បានសហការជាមួយទូរទស្សន៍ខ្សែកាប្លិ៍ បញ្ចូលទូរទស្សន៍**ទទក២** របស់ក្រសួងព័ត៌មាន និងទូរទស្សន៍ហ្វ្រេសញូ ក្នុងទូរទស្សន៍ខ្សែកាប្លិ៍ខេត្ត។ បានផ្សព្វផ្សាយព័ត៌មានតាមរយៈទូរទស្សន៍ជាតិ ទូរទស្សន៍ឯកជន កាសែតទស្សនាវដ្តី និងព្រឹត្តិបត្រផ្សេងៗអំពីសមិទ្ធផលសំខាន់ៗរបស់ប្រទេសជាតិ និងការអភិវឌ្ឍន៍ ព្រមទាំងព្រឹត្តិការណ៍នានារបស់រដ្ឋបាលខេត្តចំនួន ២.៦២០លើក បានផ្សព្វផ្សាយព័ត៌មានតាមរយៈវិទ្យុឆ្នេរកែប FM 99 MHz ចំនួន ១៥០.៦២៨លើក។

### ៦.១១.វិស័យអប់រំ យុវជន និងកីឡា:

វិស័យអប់រំ យុវជន និងកីឡាខេត្តកែប បានកំពុងផ្តល់សេវាគ្រប់ដណ្តប់លើក្រុង ស្រុកចំនួន ០២ ឃុំ សង្កាត់ចំនួន០៥ និងភូមិទាំង ១៨ ដែលមានគ្រឹះស្ថានសិក្សាសាធារណៈរបស់រដ្ឋ និងឯកជនរួមមានមត្តេយ្យសិក្សារដ្ឋក្នុងបឋមសិក្សា ២២កន្លែង បឋមសិក្សាសាធារណៈ ២២កន្លែង អនុវិទ្យាល័យ ០៤កន្លែង វិទ្យាល័យចំនួន ០២កន្លែង គ្រឹះស្ថានឧត្តមសិក្សា ០១កន្លែង (កំពុងត្រៀមដាក់ឱ្យដំណើរការនៅពេលខាងមុខ) មត្តេយ្យសហគមន៍ ០៩កន្លែង មត្តេយ្យសិក្សាឯកជន ០៣កន្លែង និងបឋមសិក្សាឯកជន ០២កន្លែង។ បុគ្គលិកអប់រំទូទាំងខេត្តកែប សរុបចំនួន **៦១៩នាក់ ស្រី ២៨៩នាក់**(ស្មើនឹង៤៦,៦៨%) ដែលក្នុងនោះក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តមសរុបចំនួន ៨៧នាក់ ស្រី ២៦នាក់ ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋានសរុបចំនួន ៤២៨នាក់ ស្រី១៩៧នាក់ ក្របខណ្ឌគ្រូបង្រៀនបឋមសិក្សាសរុបចំនួន ៨២នាក់ ស្រី ៤៥នាក់ និងក្របខណ្ឌបង្រៀនមត្តេយ្យសិក្សាសរុប ២២នាក់ ស្រី ២១នាក់។ បុគ្គលិកបង្រៀននៅតាមសាលាឯកជនសរុបចំនួន ៣៩នាក់ ស្រី ២៦នាក់។

ជារួម ចំពោះសំណង់អគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** គឺបានគ្របដណ្តប់ទូទាំងខេត្តកែប ដែលមានចំនួន **៣៤ខ្នង** ស្មើនឹង **៣៣៥បន្ទប់**។

ផ្នែកកីឡាបានចូលរួមប្រកួតកីឡានានា ជាលទ្ធផលទទួលបានជ័យលាភីមេដាយសរុបចំនួន ១៣គ្រឿង ក្នុងនោះមានមេដាយមាសសរុបចំនួន ៣គ្រឿង មេដាយប្រាក់សរុប ៥គ្រឿង និងមេដាយសំរឹទ្ធិសរុបចំនួន ៥គ្រឿង។ ចូលរួមប្រកួតប្រជែងក្នុងកម្មវិធីប្រកួតប្រជែងស្នាដៃយុវជនសតវត្សរ៍ទី២១ ក្រោមប្រធានបទ "**ការអភិវឌ្ឍវិស័យកសិកម្មតាមបែបវិទ្យាសាស្ត្រ**" ទទួលបានពានរង្វាន់ជ័យលាភីលេខ ៣ ទូទាំងប្រទេសប្រចាំឆ្នាំ២០១៩។

**៦.១២.វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ដើម្បីចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ខេត្ត ខេត្តកែបបានរៀបចំ និងដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលខេត្ត២០១៩-២០២៣ ដើម្បីលើកកម្ពស់លក្ខខណ្ឌការងារឲ្យកាន់តែប្រសើរឡើង ពង្រឹលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ ភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈបង្កើនឱកាសការងារសមរម្យ ពង្រឹងការផ្សព្វផ្សាយ និងបញ្ជ្រាបអំពីព័ត៌មានទីផ្សារការងារ អភិវឌ្ឍន៍ការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងផ្តល់សេវាបច្ចេកទេសវិជ្ជាជីវៈជូនពលរដ្ឋ។

បានធ្វើសៀវភៅការងារជូនកម្មករនិយោជិតខ្មែរ និងបរទេស ៨២៩នាក់ អធិការកិច្ចការងារតែមួយ ១៨២លើក អធិការកិច្ចចម្រុះជនបរទេស ១៩០នាក់ និងបានបណ្តុះបណ្តាលជំនាញផ្សេងៗចំនួន ២៨ ជំនាញ មានសិក្ខាកាមសរុប ៣.១៧៦នាក់ទទួលការបណ្តុះបណ្តាលនេះ។

**៦.១៣.វិស័យសុខាភិបាល:**

អ្នកជំងឺសម្រាកពេទ្យ ៨.៨៣៣នាក់, ពិគ្រោះជំងឺក្រៅ ១២៧.៧២៥នាក់, ផ្តល់ថ្នាំបង្ការដល់កុមារ និងស្ត្រី ៧.៩៧៥នាក់ ពិនិត្យផ្ទៃពោះ ១១.៨៩២នាក់, សម្រាលកូន ២.១៩០នាក់, អ្នកប្រើប្រាស់មធ្យោបាយពន្យារកំណើតបន្ត ៤.៨៧៩នាក់, បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ (ដូសទី១ទី២ សម្រាប់អាយុ ៣-៤ឆ្នាំ ១.២០៨នាក់, ដូសទី១ដល់ទី៣ សម្រាប់អាយុ ៥ឆ្នាំ ២.៥០០នាក់, ដូសទី១ដល់ទី៤សម្រាប់អាយុ ៦-១១ឆ្នាំ ១៥.៨៨៣នាក់, ដូសទី១ដល់ទី៥សម្រាប់អាយុ ១២-១៧ឆ្នាំ ១៨.៨៩៧ នាក់, ដូសទី១ដល់ទី៥សម្រាប់អាយុ១៨ឆ្នាំឡើង ៨១.១៩៧នាក់។ អ្នកជំងឺកូវីដ-១៩ ចំនួន ៦៦៥នាក់ ស្លាប់ចំនួន ១២នាក់។ បានអប់រំសុខភាពជំងឺឆ្លង និងមិនឆ្លង ២៤០លើក។

**៦.១៤.វិស័យសុខភាព និងអនាម័យជនបទ**

បានរៀបចំទិវាពិភពលោកលាងសម្អាតដៃតាមសាលាបឋមសិក្សានៅក្រុង ស្រុក ដែលមានការចូលរួមពីសំណាក់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ រួមនឹងមន្ត្រីរាជការស្ថាប័នពាក់ព័ន្ធ។ បានជីកអណ្តូងស្នប់ ចំនួន ៥១អណ្តូង ជីកស្រះទឹក ០៥កន្លែង សាងសង់បង្គន់អនាម័យ ៨៧០បង្គន់ជូនប្រជាពលរដ្ឋ។ គិតត្រឹមឆ្នាំ២០២១ ទូទាំងខេត្តបានផ្តល់សម្ភារៈបដិភាគបង្គន់អនាម័យជូនប្រជាពលរដ្ឋក្រីក្រសរុបចំនួន **១.៣២២បង្គន់។**

**៦.១៥.វិស័យសង្គមកិច្ច:**

អនុវត្តស្មារតីអនុក្រឹត្យលេខ២៤៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ សម្រេចបានលទ្ធផលៈស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ចុះឈ្មោះចូលកម្មវិធីនៅតាមរដ្ឋបាលឃុំ សង្កាត់ ចំនួន ៤២៣ នាក់ អ្នកទទួលផលបានអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ចំនួន ៣,១២៩ករណី ចំណាយទឹកប្រាក់សរុប ១៦៩,៤០០,០០០រៀល។

តាមស្មារតីអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធ

នឹងជំងឺកូវីដ-១៩ គ្រួសារមកផ្ទៀងផ្ទាត់ឈ្មោះ នៅតាមរដ្ឋបាលឃុំ សង្កាត់ បានចំនួន ២,២៨៩ គ្រួសារ ចំណាយទឹកប្រាក់សរុបចំនួន ១២,៨៧៦,៣៦៤,០០០ រៀល។

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជាជំនួយសង្គមអំឡុងពេលបិទខ្ទប់ ជូនគ្រួសារមានសមាជិកឆ្លងជំងឺកូវីដ-១៩ ដែលមានការលំបាកផ្នែកជីវភាព ត្រូវបានដាក់ឱ្យអនុវត្តតាមសារលិខិតលេខ ១៨ស.ល.ខ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១ ដែលសម្រេចលទ្ធផលៈបានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារប្រជាពលរដ្ឋមានសមាជិកឆ្លងជំងឺកូវីដ-១៩ ដែលមានការលំបាកផ្នែកជីវភាព ចំនួនពីរលើក ស្មើនឹង ១៦០ គ្រួសារ ចំណាយទឹកប្រាក់សរុប ៤៥.៥២១.៨០០រៀល បានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារ ដែលមានសមាជិកស្លាប់ដោយសារជំងឺកូវីដ-១៩ ចំនួន ០៣គ្រួសារ ចំណាយទឹកប្រាក់សរុប ២.៤៥៦.៥០០រៀល។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា នៅក្នុងខេត្តកែបសរុប ៦១៩គ្រួសារ សមាជិកសរុបចំនួន ១,៤៨៥នាក់ ស្រី ១,១១៣នាក់។ ជាលទ្ធផលគ្រួសារមកបើកប្រាក់ឧបត្ថម្ភនៅក្នុងដំណាក់កាលទី០១ នៅតាមបញ្ជរវីងចំនួន ៥៨៣គ្រួសារ ស្មើនឹង៩៤% នៃចំនួនគ្រួសារសរុប ដែលមានសមាជិកសរុបចំនួន ១,៤១២នាក់ ស្រី ១,០៥២នាក់ ចំណាយទឹកប្រាក់សរុបចំនួន ៧៩,៧០៩,៩០០រៀល។

-បានប្រគល់ផ្ទះទំហំ ៤ម៉ែត្រ គុណ ៩ម៉ែត្រ ជូនអតីតយុទ្ធជនដែលមានជីវភាពក្រីក្រចំនួន ១៦គ្រួសារ ស្មើនឹង ១៦ខ្នងផ្ទះ។

## ៦.១៦.វិស័យកិច្ចការនារី

- រៀបចំពិធីអបអរសារទិវានារីអន្តរជាតិ ៨មីនា ចំនួន ០៥លើក មានអ្នកចូលរួមសរុបចំនួន ២,២២១នាក់ (ស្រី ១,៧៩៨នាក់)។

- វគ្គផ្សព្វផ្សាយ៖ សេវាសុខភាពអនាម័យ ទូទៅ និងអាហារូបត្ថម្ភ, អាហារូបត្ថម្ភ និងការបន្តពូជ, បញ្ហាប្រឈមនៅក្នុងសង្គម និងផលប៉ះពាល់អវិជ្ជមានលើយុវវ័យ, ការរៀបអាពាហ៍ពិពាហ៍វ័យកុមារ និងការចិញ្ចឹមកូនបែបវិជ្ជមាន ៩លើក អ្នកចូលរួមចំនួន ១,០០៦នាក់ ស្រី ៧០៥នាក់។

- រៀបចំវេទិកាពិគ្រោះយោបល់ស្តីអំពី បញ្ហាប្រឈមក្នុងសង្គម និងផលប៉ះពាល់អវិជ្ជមានលើយុវវ័យ, ការលើកកម្ពស់សីលធម៌សង្គមនាំមកនូវសេចក្តីថ្លៃថ្នូរ សន្តិភាព និងការអភិវឌ្ឍន៍១០លើក អ្នកចូលរួមចំនួន ១,២៦២នាក់ ស្រី ៦៨៩នាក់។

- ចុះផ្សព្វផ្សាយស្តីពីសុវត្ថិភាពចរាចរណ៍ ដើម្បីរួមគ្នាកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ វិធីការពារប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ចែកផ្ទាំងរូបភាព សាប៊ូដុំ និងផ្សព្វផ្សាយការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី១ រហូតដល់ដូសជំរុញ ១៥លើក។

- វគ្គផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានាលើស្ត្រី និងកុមារ, ការទប់ស្កាត់អំពើរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ, ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងប្រថុយប្រថាន, ការជួញដូរស្ត្រី និងកុមារ ផលប៉ះពាល់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ១៧លើក អ្នកចូលរួមចំនួន ១,៩៥៨នាក់ ស្រី ១,២៣០នាក់។

- បើកវគ្គបណ្តុះបណ្តាលស្តីពីៈ សកម្មភាពថ្នាក់ភូមិ ការទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ និងរាល់ទម្រង់នៃការកេងប្រវ័ញ្ច, ការទប់ស្កាត់អំពើរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ, ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ០៦លើក អ្នកចូលរួមចំនួន ២៧៥នាក់ ស្រី ២៤២នាក់។

## ៦.១៧.វិស័យធម្មការ និងសាសនាៈ

ទូទាំងខេត្តមានវត្តចំនួន ១៧វត្ត ក្នុងនោះវត្តគណៈធម្មយុត្តិកនិកាយចំនួន ០២វត្ត(ទើបបង្កើតថ្មីនៅឆ្នាំ២០១៧ និងឆ្នាំ២០១៩) និងមជ្ឈមណ្ឌលវិបស្សនាធុរៈ ០១កន្លែង វិហារឥស្លាម ០២កន្លែង សាសនាគ្រឹស្ត ០៥កន្លែង វិហារថៅកុងចិន ០៤កន្លែង។ មានកម្រងសាលាពុទ្ធិកបឋមសិក្សា ១កន្លែង មាន ០៥ថ្នាក់ និងបានរៀបចំការប្រឡងធម្មវិន័យថ្នាក់ ត្រី ទោ ឯក ជារៀងរាល់ឆ្នាំ។ បានផ្សព្វផ្សាយច្បាប់សារាចរ សេចក្តីណែនាំ និងសង្ឃប្រកាសដល់គ្រប់វត្តអារាម វិហារសាសនា និងស្នាក់ការថ្វាយបង្គំ និងបានធ្វើការធ្វើការផ្សព្វផ្សាយ និងអប់រំដល់ពុទ្ធបរិស័ទ យុវជន យុវនារី សិស្សានុសិស្ស អំពីបញ្ហាគ្រឿងញៀន ការលេងល្បែងស៊ីសង និងវិធានការការពារជំងឺកូវីដ-១៩ តាមរយៈការទេសនារបស់ព្រះសង្ឃ។

នៅក្នុងរយៈពេល ៥ឆ្នាំនេះ នៅតាមបណ្តាវត្តអារាម ទូទាំងខេត្តបានកសាងរួមមាន បានកសាងរួចរាល់ព្រះវិហារ ០១កន្លែង កុដិ ៧ខ្នង សាលាបាលី ១អគារកម្ពស់ ២ជាន់ ឧបដ្ឋានសាលា ០៥ខ្នង បន្ទប់ទឹក ២២បន្ទប់ និងកំពុងដំណើរការសាងសង់កុដិ ០៥ខ្នង ព្រះវិហារ ២កន្លែង និងឧបដ្ឋានសាលា ៤ខ្នង។

## ៦.១៨.វិស័យវប្បធម៌ និងវិចិត្រសិល្បៈ

ដើម្បីសម្រេចបាននូវកិច្ចការងារ អភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិ ស្របតាមគោលបំណងគោលនយោបាយ វប្បធម៌ជាតិ និងបន្តចូលរួមជំរុញថែរក្សា ការពារលើកតម្កើងកេរ្តិ៍តំណែលវប្បធម៌ជាតិ អភិវឌ្ឍន៍សកម្មភាពវប្បធម៌គ្រប់ជំនាញ លើកទឹកចិត្តស្នាដៃបង្កើតថ្មី ព្រមទាំងអប់រំអំពីវប្បធម៌ និងសីលធម៌ដ៏ល្អប្រពៃរបស់ជាតិ ទប់ស្កាត់ការហូរចូលឥតឈប់ឈរនៃវប្បធម៌អវិជ្ជមានពីបរទេស កាត់បន្ថយសកម្មភាពមិនល្អក្នុងស្រទាប់យុវជនដែលធ្វើឲ្យប៉ះពាល់ដល់វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ដ៏ល្អផូរផង់របស់ជាតិ ជាពិសេសដើម្បីបម្រើឲ្យយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលវិស័យវប្បធម៌ និងវិចិត្រសិល្បៈខេត្តកែបបានខិតខំ និងសហការជាមួយស្ថាប័នរដ្ឋ សមាគម អង្គការ សង្គមស៊ីវិល វិស័យឯកជន ក្នុងគោលបំណងប្រែក្លាយវប្បធម៌ជាសេដ្ឋកិច្ចជាតិ។

ជាក់ស្តែងមានការខិតខំនិពន្ធ និងដំឡើងស្នាដៃសិល្បៈទស្សនីយភាព ការប្រគំភ្លេង និងសំដែងទស្សនីយភាពសិល្បៈ ការដឹកនាំក្រុមសិល្បៈទៅចូលរួមមហោស្រពនៅថ្នាក់ជាតិ រៀបចំមហោស្រពសិល្បៈរបាំ វង់ភ្លេងគ្រប់ទម្រង់..។ល។

## ៦.១៩.ការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

បានចូលរួមអង្កេតស្រាវជ្រាវលើពាក្យបណ្តឹងជំទាស់ ០៣លើក ពិនិត្យ និងទទួលស្រាវជ្រាវពាក្យបណ្តឹងតាមរយៈក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ០១លើក បានសហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ស្តីពីការធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមបណ្តាមន្ទីរ អង្គភាពក្នុងខេត្តបានចំនួន ២០លើក ធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមបណ្តាមន្ទីរ ៥៤លើក ផ្សព្វផ្សាយច្បាប់ផ្សេងៗមានអ្នកចូលរួមសរុប ៧.៣៧៣នាក់ ស្រី ៤.៧៤៨នាក់ ធ្វើវេទិកា

សាធារណៈមានអ្នកចូលរួមសរុប ៤០០នាក់ ស្រី ១៧៣នាក់ ចុះស្ទង់មតិប្រជាពលរដ្ឋអំពីការយល់ដឹងលើច្បាប់ ០២លើក មានអ្នកចូលរួមសរុប ៦៤៥នាក់ ស្រី ៤៦៩នាក់។

**៦.២០.វិស័យដីធ្លី**

អំពីរបាយការណ៍សង្ខេបសមិទ្ធផលសំខាន់ៗ និងសូចនាករសម្រេចបានរយៈពេល ៥ឆ្នាំ (២០១៨-២០២២) មានដូចខាងក្រោម៖

**ផ្នែកសុរិយោដី** ការចុះបញ្ជីលើកដំបូង **១២៧ប័ណ្ណ**, ចុះបញ្ជីបន្ត **៤.៦៤៥ប័ណ្ណ**, ចុះបញ្ជីតាមលក្ខណៈជាប្រព័ន្ធ **៤១.៩៣០ប័ណ្ណ**។

**ផ្នែករៀបចំដែនដី** បានធ្វើផែនការប្រើប្រាស់ដីធ្លីគ្រប់ភូមិទូទាំងខេត្ត និងធ្វើប្លង់គោលស្រុកដំណាក់ចម្លើរសម្រេចបាន ១០០% ការកសាងប្លង់ទីប្រជុំជន និងការកសាងផែនទីប្រើប្រាស់ដីធ្លីព្រំប្រទល់ឃុំ សង្កាត់ និងហេដ្ឋារចនាសម្ពន្ធគ្រប់ឃុំ សង្កាត់។

**ផ្នែកសំណង់** បានចេញលិខិតអនុញ្ញាតសាងសង់សំណង់សណ្ឋាគារ ខុនដូ ផ្ទះសំណាក់ ផ្ទះសំណាក់ បុរី សំណង់អគារផ្សេងៗចំនួន **៦៩គម្រោង**។

**៦.២១.ការធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ**

ធានាបានសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈបានល្អប្រសើរជូនឥស្សរជនជាន់ខ្ពស់រាជរដ្ឋាភិបាល គណៈប្រតិភូជាតិ អន្តរជាតិ ដែលមកបំពេញបេសកកម្មនៅខេត្ត ព្រមទាំងភ្ញៀវទេសចរជាតិ អន្តរជាតិ ដែលមកទស្សនា សម្រាក លម្ហែ កំសាន្តក្នុងខេត្ត។ ជាមួយនេះ បានមានវិធានការទប់ស្កាត់អំពើជួញដូរមនុស្ស ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ការបំផ្លិចបំផ្លាញធនធានធម្មជាតិ។ល។ តាមរយៈការដាក់ចេញនូវវិធានការសមស្របតាមគោលការណ៍ច្បាប់ ដើម្បីការបង្ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសគ្រប់ប្រភេទផ្សេងៗ។

**បទល្មើសព្រហ្មទណ្ឌ៖** កើតឡើង ៧៤ករណី ជនសង្ស័យ ១១៣នាក់ ក្នុងនោះ បទឧក្រិដ្ឋ ១២ករណី ជនសង្ស័យ ២៣នាក់ ស្រី ០១នាក់ បទមជ្ឈិម ៦២ករណី ជនសង្ស័យ ៩០នាក់។

**ការងារប្រឆាំងគ្រឿងញៀន៖** បង្ក្រាប ១៧៧ករណី ឃាត់ខ្លួនជនសង្ស័យ ៣៥៣នាក់ ស្រី ១៦នាក់ និងដកហូតវត្ថុតាងមួយចំនួន។

**ការបង្ក្រាប៖** បានចំនួន ៥៨ករណី ឃាត់ខ្លួនជនសង្ស័យ ៧៩នាក់ ក្នុងនោះ បទឧក្រិដ្ឋ ១០ករណី ជនសង្ស័យ ១២នាក់ បទមជ្ឈិម ៤៨ករណី ជនសង្ស័យ ៦៧នាក់។ ជនសង្ស័យខាងលើត្រូវបានបញ្ជូនទៅសាលាដំបូងខេត្ត ៧៩នាក់ នឹងធ្វើការអប់រំ ៥៤នាក់។

**គ្រោះថ្នាក់ចរាចរណ៍៖** ចំនួន ២៨៣លើក បណ្តាលឲ្យមនុស្សស្លាប់ ៦៣នាក់ របួសធ្ងន់ ស្រាល ៤៩៩នាក់។ គ្រោះថ្នាក់សង្គម៖ ១១៤លើក បណ្តាលឲ្យមនុស្សស្លាប់ ៩៤នាក់។

III-**សេចក្តីសន្និដ្ឋាន**

-**ចំណុចខ្លាំង**

មានសន្តិភាព ស្ថេរភាពនយោបាយជាសសរស្តម្ភដ៏រឹងមាំសម្រាប់ការអភិវឌ្ឍន៍ និងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ វិនិយោគិន អ្នកទេសចរជាតិ អន្តរជាតិ ក្រោមការដឹកនាំប្រកបដោយភាពប៉ិនប្រសប់និងឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់ទី៤ ផែនការយុទ្ធសាស្ត្រ

អភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ និងកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ដែលជះឥទ្ធិពលក្នុងការអភិវឌ្ឍន៍។ ជាមួយនេះ ការដំឡើងប្រាក់បៀវត្សរ៍ បេឡាជាតិរបបសន្តិសុខសង្គម ធ្វើឲ្យមន្ត្រីមានធន្ទះខិតខំបំពេញការងារផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយគុណភាព និងប្រសិទ្ធភាព។

មានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ការចុះជួយប្រជាពលរដ្ឋតាមខ្នងផ្ទះពេលមានគ្រោះមហន្តរាយដោយធម្មជាតិ ជំងឺជង្កាត់ផ្សេងៗពិសេសជំងឺកូវីដ-១៩ កន្លងមកបានទាន់ពេលវេលា ក្តាប់បានទុក្ខកង្វល់ ទទួលយកសំណើ សំណូមពរ រកដំណោះស្រាយ ដើម្បីឆ្លើយតបតម្រូវការជាក់ស្តែងជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ស្របតាមគោលការណ៍នៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**-ចំណុចខ្វះខាត**

ធនធានមនុស្សពុំទាន់ឆ្លើយតបទៅនឹងទំហំការងារ ការផ្តល់សេវា និងការអភិវឌ្ឍ បញ្ហាគ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍នៅតែកើតមាន អ្នកវិនិយោគមិនមកធ្វើការវិនិយោគគម្រោងរបស់ខ្លួនឱ្យបានព្រមគ្នានៅក្នុងភូមិសាស្ត្រខេត្ត ដែលនាំឱ្យមានការរាំងស្ទះដល់ការអភិវឌ្ឍ និងមិនទាន់ឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋាន។

ជារួមទោះបីមានចំណុចខ្វះខាតមួយចំនួន រដ្ឋបាលខេត្តអនុវត្តសម្រេចបានលទ្ធផលគួរជាទីមោទនៈ ដោយរក្សាបានសុខសុវត្ថិភាព ជូនឥស្សរជនជាតិ អន្តរជាតិ ភ្ញៀវទេសចរជាតិ អន្តរជាតិ និងប្រជាពលរដ្ឋ បង្កើនមុខរបរ សេដ្ឋកិច្ច ជីវភាព កាត់បន្ថយចំណាកស្រុក ពិសេសកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋពី ១២,៨៤% នៅឆ្នាំ២០១៧ មកត្រឹម ២,៦១% នៅឆ្នាំ២០២២។

IV-**ទិសដៅអនុវត្តបន្ត**

-បន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួនរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តដែលមាននៅជាធរមាន

-ថែរក្សាសន្តិភាព អនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព

-បន្តអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់ទី៤ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ និងយុទ្ធសាស្ត្របន្ទាប់ក្រោយការបោះឆ្នោតជាតិ ឆ្នាំ២០២៣ ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ឱ្យបានខ្ជាប់ខ្ជួន

-បន្តអនុវត្តឲ្យមានប្រសិទ្ធភាពច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់

-រៀបចំផែនការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៃរដ្ឋសភា ឱ្យទទួលបានលទ្ធផលល្អប្រសើរ

-គ្រប់គ្រងអង្គការសង្គមស៊ីវិល តាមច្បាប់ស្តីពីអង្គការ សមាគមមិនមែនរដ្ឋាភិបាល

-បន្តប្រយុទ្ធប្រឆាំងជំងឺឆ្លង និងជំងឺមិនឆ្លង តាមរយៈចុះផ្សព្វផ្សាយ អប់រំណែនាំប្រជាពលរដ្ឋនៅមូលដ្ឋាន តាមសារអប់រំណែនាំរបស់ក្រសួងសុខាភិបាលជាប្រចាំ

-បន្តចុះក្តាប់បញ្ហាទុក្ខកង្វល់ សំណើ សំណូមពរ រកដំណោះស្រាយ ដើម្បីឆ្លើយតបតម្រូវការជាក់ស្តែងជូនប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យបានសកម្មថែមទៀត

-ត្រៀមអនុវត្តផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តកែប ២០២១-២០៣៥ ឱ្យទទួលបានលទ្ធផលប្រសើរ

-អនុវត្តឱ្យមានប្រសិទ្ធភាពនូវប្លង់គោលប្រើប្រាស់ដីក្រុងកែប ចក្ខុវិស័យឆ្នាំ២០៣០

-សហការជាមួយដៃគូ និងវិស័យឯកជនក្នុងការអភិវឌ្ឍន៍ខេត្ត។

**សាជាថ្មីម្តងទៀត** ខ្ញុំបាទ សូមគោរពថ្លៃងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **ឯកឧត្តម ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានផ្តល់ឱកាសឱ្យខេត្តកែបបានមកចែករំលែកនូវព័ត៌មាន ស្តីពីភាពជោគជ័យ និងបង្ហាញជូននូវសមិទ្ធផលសម្រេចបានក្នុងរយៈពេល ០៥ឆ្នាំ (២០១៨-២០២២)របស់ខេត្តកែប ជូនដល់ថ្នាក់ដឹកនាំ និងបងប្អូនប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានក្នុង និងក្រៅប្រទេស ពិសេសប្រជាពលរដ្ឋខេត្តកែបដែលបានកំពុងទស្សនាការ Live ផ្ទាល់តាមប្រព័ន្ធ Online Social Media ក្នុងអង្គសន្និសីទសារព័ត៌មានដ៏មានសារសំខាន់នាពេលនេះ។

**ជាទីបញ្ចប់** ខ្ញុំបាទសូមគោរពជូនពរ **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល** សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងពលំ មាំមួន ប្រាជ្ញាឈ្លាសវៃ ទទួលបានជោគជ័យគ្រប់ភារកិច្ច និងសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មាននៅទីនេះ ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ សូមបានសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺៈ ***អាយុ វណ្ណៈ សុខៈ និងពលៈ*** កុំបីឃ្លៀងឃ្លាតឡើយ។

**ខ្ញុំសូមជូនកម្មវិធីទៅបងប្អូនអ្នកសារព័ត៌មាន ដើម្បីលើកជាសំណួរពាក់ព័ន្ធប្រធានបទ យើងខ្ញុំជាវាគ្មិននឹងឆ្លើយបំភ្លឺជូនតាមសំណួរនីមួយៗ។**

***សូមអរគុណ!***